# អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍
# Action for Research and Development

សមត្ថភាព គុណភាព តម្លាភាព
Capacity Quality Transarency

ផ្ទះលេខ ៥១F ផ្លូវ ២៦៥ សង្កាត់ ទឹកល្អក់ ៣
ខណ្ឌទួលគោក ក្រុងភ្នំពេញ កម្ពុជា
ទូរសព្ទ័លេខ: ០១៦ ៧៧៨ ៧០១
អ៊ីម៉ែល: ard.cambodia@yahoo.com
ard.info@yahoo.com
ប្រអប់សំបុត្រ: CCC ៣០៥

# ពត៌មានសំខាន់សំរាប់អ្នក
# Necessary News for You

## ព្រឹត្តិបត្រព័ត៌មានប្រចាំខែ
## Monthly Newsletter

## មាតិកាពត៌មាន

❖ អ្វីទៅជា ARD? .......... 2
❖ ជំណឹងជ្រើសរើសបុគ្គលិកសង្ខេប.......... 3
❖ ជំងឺផ្តាសាយបក្សី និងការអប់រំ ផ្សព្វផ្សាយ.......... 5
❖ ផលប៉ះពាល់នៃថ្នាំពុលកសិកម្មទៅលើសុខភាព.......... 5
❖ ការស្វែងយល់ពីកិច្ចការពារបរិស្ថាននៅប្រទេសជប៉ុន.......... 7
❖ និមិត្តរូបបាតដៃស្អាតស្អំ និងអំពើពុករលួយនៅក្នុងសង្គមកម្ពុជា..... 8
❖ ភាពពិត នៃកីឡាកម្ពុជា.......... 9
❖ ជំរើសល្អសំរាប់យុវវ័យ.......... 10

ចែកជូនដោយឥតគិតថ្លៃ

# តើអ្វីទៅជា ARD ?

## ប្រវត្តិអង្គការ

អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និង អភិវឌ្ឍន៍ (Action for Research and Development) ហៅកាត់ថា **ARD** គឺជាអង្គការក្រៅរដ្ឋាភិបាល មិនស្វែង រកប្រាក់ចំនេញដែលប្រកបទៅដោយជំនាញបច្ចេក-ទេសកសិកម្ម និងអភិវឌ្ឍជនបទ រួមជាមួយនឹងការអភិរក្សធនធានធម្មជាតិ និង បរិស្ថានអោយមាននិរន្តរភាព។

**ARD** ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ២០០៥ ដោយសមាជិកស្ថាបនិកចំនួន ៦រូប ដែលមានជំនាញ និងបទពិសោធន៍ ព្រមទាំងមានការគាំទ្រពីសំនាក់ សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់៥រូប និងបុគ្គលិកស្ម័គ្រចិត្ត ១០រូប។ យើងទាំងអស់គ្នាមាន ការតាំងចិត្តខ្ពស់ដើម្បីធ្វើការអភិវឌ្ឍន៍ និងអភិរក្ស ដើម្បីធ្វើអោយជីវភាពរស់ នៅរបស់ប្រជាជនក្រីក្រនៅក្នុងសហគមន៍មានការកើនឡើង។អង្គការមានបាវចនា សមត្ថភាព គុណភាព និង តម្លាភាព ដែលបញ្ជាក់ ពីការប្តេជ្ញាចិត្តខ្ពស់ និងការទទួលខុសត្រូវ ដើម្បីសំរេចនូវបេសកកម្ម ប្រកបដោយលទ្ធផលដ៏អស្ចារ្យ ដែលនឹងផ្តល់ផលប្រយោជន៍ទៅកាន់ក្រុមគោលដៅរបស់ពួកយើងនិងធ្វើជាគំរូដ៏ល្អសំរាប់ការអនុវត្តន៍តាម ។

## សេវាកម្ម

អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និង អភិវឌ្ឍន៍ មានផ្តល់នូវសេវាកម្មបណ្តុះបណ្តាល ផ្សព្វផ្សាយ ស្រាវជ្រាវសង្កេត និងវាយតំលៃ ទៅតាមតំរូវការចាំបាច់ របស់អង្គការ-ស្ថាប័ននានា សំដៅពង្រឹងបន្ថែមនូវសមត្ថភាពបុគ្គលិកនិងការអនុវត្តន៍គំរោងរបស់ខ្លួនប្រកបដោយ គុណភាព និងប្រសិទ្ធិភាព ។

## ទស្សនៈវិស័យ

ចូលរួមធ្វើអោយសង្គមកម្ពុជាមួយ ដែលប្រជាពលរដ្ឋមានសមត្ថភាពប្រកបដោយគុណភាព និងប្រសិទ្ធិភាព ចេះជួយគ្នាទៅវិញទៅមក ព្រមទាំងរស់នៅក្នុងជីវភាពមួយ ដែលមានលក្ខណៈថ្លៃថ្នូរ ពោរពេញទៅដោយ បរិស្ថានល្អ។

## បេសកកម្ម

សមត្ថភាព និងគុណភាពរបស់និស្សិតត្រូវបានបង្កើន ដែលនាំអោយពួកគេចូលរួមចំណែកប្រកបដោយប្រសិទ្ធីភាពនៅក្នុងការអភិវឌ្ឍន៍សង្គមកម្ពុជា ដែលមាននិរន្តរភាព តាមរយៈការផ្តល់អំណាច និងធ្វើការជាមួយប្រជាកសិករក្រីក្រនៅតំបន់ជនបទ ។

## កម្មវិធី

ក. កម្មវិធីកសាងសមត្ថភាព ស្រាវជ្រាវ និងបោះពុម្ពផ្សាយ

គឺជាថ្នាលបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ដល់ប្រជាពលរដ្ឋទូទៅ ជាពិសេសសិស្ស-និស្សិត ក្នុងគោលបំណងអោយពួកគេទទួលបាននូវចំណេះដឹង និងបទពិសោធន៍ ដ៏មានប្រសិទ្ធិភាព ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គមកម្ពុជាអោយទទួលបានជោគជ័យ ។

**ខ. កម្មវិធីអភិវឌ្ឍន៍សហគមន៍ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន**

មានគោលដៅដើម្បីចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាកសិករ នៅតំបន់ជនបទតាមរយៈការបណ្តុះបណ្តាល ផ្សព្វផ្សាយបច្ចេកទេសកសិកម្មសមស្រប, ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព និងការចងក្រងក្រុមកសិករ-សហគមន៍ ដោយផ្តល់នូវសិទ្ធិអំណាចពេញលេញ ក្នុងការធ្វើសេចក្តីសំរេចចិត្តនានា ក្នុងគោលដៅលើកស្ទួយកំរិតជីវភាពរស់នៅរបស់គ្រួសារ និងសហគមន៍របស់ខ្លួន ។

# ទំព័រឱកាសសំរាប់អ្នក

## Brief Job News

**WVC** : Transformational Development Facilitator
**ARD** : Trainees
**LWF** : Community Empowerment Facilitator
**Oxfam-GB** : Humanitarian Program Assistant
**SABORAS** : Credit Project Assistant
**COMFRE** : Monitoring Officer
**EC** : Program Officer for Food Security
**CIAI** : Communication Officer
**NGO Forum:** Land, Livelihoods Programme Adviser

**World Vision Cambodia (WVC)** is a Christian relief and development organization committed to Working with poor communities, focused on children, to transform lives and Cambodian society through sustainable development. We are seeking for (26) qualified Cambodian to fill the positions of **Transformational Development Facilitator (TDF)** based in Kampong Chhnang Operations and 21 qualified Cambodian based in Battambang Operations..

- Three (3) positions based in Chulkiri district.
- Five (5) positions based in Kampong Tralach district.
- Six (6) positions based in Kampong leang district.
- Six (6) positions based in Samaki Mean Chey district.
- Six (6) position based in Boribo district.
- Three (3) positions based in Kohkrolor district.
- Five (5) positions based in Banan district.
- Three (3) positions based in Rattanak Mondol district.
- Seven (7) positions based in Samlot district.
- One (1) position based in Battambang district.
- Two (2) positions based in Phnom Prek district.

**The Essential Requirements for the position are:**

- At least high school for general education
- Preferably has at least one year experience in working with the poor communities
- Preferably has experience mobilizing and training youth

The successful workshop candidates are required to have a field test and stay one night in the village. Interested applications should obtain as official WVC's application form and submits it with CV and Cover Letter to HR Department, World Vision Cambodia or email to the following address. Qualified women and disabled people are encouraged to apply

**Closing Date: 13-Oct-2006**

**Contact Details:**

**HR Department, World Vision Cambodia**
# 20, Street 71, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh.
Tel. : 023 216 052 (Office)
E-mail: cam_recruitment@wvi.org

**World Vision Cambodia, Kampong Chhnang Office**
Damnakporpol Village, Kg.Chhnang district, Kampong Chhnang. Address: Damnakporpol Village, Kg.Chhnang district, Kampong Chhnang. Tel. : 026 770 012 (Office)

**World Vision Cambodia, Battambang Office**
Address: Chreykong Village, Battambang district, Battambang. Tel. : 053 952 394 (Office)

# ដំណឹងជ្រើសរើសបុគ្គលិក

**Action for Research and Development** 'ARD' is a not-for-profit research and development non-governmental organization contributed in **Capacity Building for Young Graduates** and specialized in the field of ecological agriculture and rural development with sustainable natural resource and environmental management. ARD have a plan to conduct a new training course on **Community Development Works** which will take place in the weekend (only four hours per weekend). The training will start on 04 November 2006 and facilitate by experience Facilitators/Trainers from expertise Local, International and UN organizations. The trainees will join in the training course in the period of 6-8 weeks in training class and on the job training at the field. The trainees for this Training are **20** (Twenty). The main topics of the Community Development Works training course are:

- Community Development Concepts
- How to work with the poor in the community
- Effective Team Work and Networks
- Planning, Implementation, Monitoring and Evaluation Concepts
- Problem Identification and Solving
- Gender Concept and Participatory Approach

All students from various Universities in Cambodia who **interested in this subject** are strongly encourage to apply for participating this training course by sending **an updated CV with Letter of Interest** in the subject to ARD office: house # 51F, St 265, Teuk Laak3, Tuol Kuok or through email: ard.cambodia@yahoo.com **not later than 25 October 2006**. For more information please contact through phone number 016 77 87 01.

---

**The Lutheran World Federation (LWF)** is opening six Integrated Rural Development through Empowerment Project (IRDEP) in the Province of Battambang, Kampong Chhnang and Kampong Speu. The overall goal of the IRDEPs is to empower the rural communities. LWF Cambodia's looking for Cambodian National for the following position **Community Empowerment Facilitator (CEF) based in IRDEP Thpong, Kg. Speu Province (2 positions)**

The Essential Requirements for the position are:

- At least two years experience in development, especially in rural community development works
- Graduated related field of Agronomy, Credit, Health

Qualified and interested candidates are invited, especially women are encouraged to apply for CEF. More information and job application form can be obtained at the LWF office: #37, Street 592, Khan Tuol Kork, Phnom Penh or for CEF can submit at Anlong Chey village, Prambeimum commune, Thpong district, Kampong Speu province.

**Deadline: October 17, 2006 at 5:30 pm**

# ទំព័រឱកាសសំរាប់អ្នក

# ដំណឹងជ្រើសរើសបុគ្គលិក

## Brief Job News Continue….

**Oxfam** works with others to overcome poverty and suffering. Now we are seeking for **Humanitarian Program Assistant** for drought preparedness Based in Kampong Speu and Svay Rieng Provinces.

**Requirements:**

- At least two years experiences working for rural development and humanitarian
- Project management
- Facilitation, design and organize training or workshop
- Knowledge of computer operation

Job Profile is available at Oxfam GB office. Please submit your Application Letter and CV to the below address. Only short listed candidates will be contacted for an interview

**Address:** #442, Street 193, Sangkat Toul Svay Prey, Phnom Penh. P.O. Box 883, Phnom Penh
Tel.: 023 212 353 (Office), 023 212 354 (Office)
**Deadline: 17-Oct-2006**

---

**SABORAS** is a non-government and non-political organization implementing community development activities in Battambang Province. SABORAS is seeking a Cambodian national applicant for the **Credit Project Assistant**.

The Essential Requirements for the position are

- University degree in Economics, Accounting, Management or a relevant field
- At least two years experiences in managing micro credit/community saving bank projects and have basic on agriculture

All interested applicants should submit a cover letter and detail curriculum vitae attachment, copy relevant certificate, references to the SABORAS office. Only short-listed candidate will be contacted for interview. CV will not be returned

**Address:** P.O. Box 318, Battambang
**Closing Date: 18-Oct-2006**

---

The Committee for Free and Fair Elections in Cambodia **(COMFREL)** is urgently seeking a suitable Cambodian candidate to fill a position of Monitoring Officer based in Phnom Penh.

The Essential Requirements for the position are:

- University degree in related field, preferably in Political Science or Law
- Good commend of English both writing and speaking
- Be available at weekends and holidays if required

Qualified applicants should submit a current CV with cover letter and contact information to COMFREL office as the address below.

Voluntarily posts are also available at COMFREL Office. Fresh graduated students (especially in Law & Political Sciences) are strongly welcomed.

Address: # 138, Street 122, Toeuk Laak I, Tuol Kork, Phnom Penh. **Closing Date: 20-Oct-200**

---

**The Delegation of the European Commission to Cambodia** is seeking highly qualified candidates for the position: **Program Officer for Food Security** who will be responsible for the administration and monitoring of a portfolio of Food Security and related EC-assisted projects within the Development Cooperation Section of the Delegation. **Requirements:**

- A good understanding of humanitarian and development aid in the context of Cambodia
- Fluent spoken and written Khmer; excellent command of English (written and spoken)

A detail job description for the positions can be found on the Delegation's website at **www.delkhm.cec.eu.int.**

**Applications:** Letter of motivation and CV - quoting reference number of the position applied for - should be addressed to the Head of Administration. Delegation of the European Commission, No 1, St.21, Phnom Penh. Application should either be hand dlivered or sent by email to **Delegation-Cambodia@cec.eu.int**. All applications will be acknowledged

**Deadline: Wednesday, November 1, 2006 at 17.00h**

---

**CIAI- Italian Association for Aid to Children** is running a Sponsorship Program in Cambodia since 1997 with the aim of ensuring education to school aged underprivileged children. Now we're looking for **Communication Officer** for Sponsorship Program

The Essential Requirements for the position are

- University Certificate
- Working experience in NGO related field
- Fluency in English (Speaking and Writing)

Interested candidates can submit CV and cover letters to contact name at the address below.

CIAI, # 2, Street 135, Sangkat Boeung Traback,
**Contact Name:** Huot Vichheka (Sponsorship Program Coordinator)
**Contact Numbers:** 023 217 996 (Office)
**Deadline:15-Oct-2006**

---

**The NGO Forum** on Cambodia is an NGO membership organization representing NGO viewpoints on development issues. The NGO Forum is currently seeking to employ a full-time expatriate **Land and Livelihoods Programme Adviser**

The Essential Requirements for the position are

- A post-graduate degree, preferably in a field related to law, land and/or natural resources management
- At least five years working in developing countries on land issues, or indigenous people's rights

A detailed job description is available upon request from the NGO Forum office. Female applicants will be given special consideration. Only short-listed candidates will be contacted. Interested candidates should send their CV and cover letter to First Floor, #9-11, Street 476, Phnom Penh. **Deadline:24-Oct-2006**

# កសិកម្ម និងការអភិវឌ្ឍន៍

## ជំងឺផ្តាសាយបក្សី និងការអប់រំផ្សព្វផ្សាយ

ចាប់តាំងពីការផ្ទុះឡើងនូវជំងឺផ្តាសាយបក្សីនៅក្នុងព្រះរាជាណាចក្រកម្ពុជាលើកដំបូងនាចុងខែមករា ឆ្នាំ២០០៤ នៅកសិដ្ឋានជាយក្រុងភ្នំពេញដែលរហូតមកដល់បច្ចុប្បន្ននេះ ជំងឺនេះបានឆ្លង និងធ្វើអោយប្រជាពលរដ្ឋខ្មែរស្លាប់ចំនួន៦នាក់នោះមក ការផ្សព្វផ្សាយអប់រំអោយយល់ដឹងជាទូទៅអំពីជំងឺនេះ បាននឹងកំពុងដំណើរការយ៉ាងសកម្មគ្រប់ដណ្តប់នៅទូទាំងព្រះរាជាចក្រកម្ពុជា តាមរយៈការដើរតួស្នូលរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសុខាភិបាល។

គួរបញ្ជាក់ផងដែរថា ជំងឺផ្តាសាយបក្សីបានផ្ទុះឡើងកាលពីចុងឆ្នាំ ២០០៣ ហើយដល់ចុងខែកញ្ញាឆ្នាំ ២០០៦ មានប្រទេសជាច្រើនបានទទួលរងនូវការឆ្លងរាលដាលដោយបណ្តាលអោយបក្សីជាច្រើនរយពាន់ក្បាលត្រូវងាប់ និងសម្លាប់ និងមានការខាតបង់ថវិការាប់ពាន់លានដុល្លារព្រមទាំងបានឆ្លងទៅមនុស្សចំនួន ២៥៦នាក់ក្នុងនោះបណ្តាលអោយស្លាប់ចំនួន ១៥៤នាក់ ដោយឡែកសំរាប់ប្រទេសឥណ្ឌូនេស៊ីមួយ មានប្រជាពលរដ្ឋស្លាប់ដោយសារការឆ្លងជំងឺផ្តាសាយបក្សីនេះរហូតដល់ទៅ ៥២ នាក់។

ដើម្បីបន្តនូវវិធានការទប់ស្កាត់ និងការពារជំងឺផ្តាសាយបក្សីអោយកាន់តែខ្លាំងក្លាឡើងថែមទៀត រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការអំពាវនាវអោយមានការចូលរួមពីព្រះសង្ឃក្នុងការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋ នូវការយល់ដឹងអំពីគ្រុនផ្តាសាយបក្សីដែលជាជំងឺមួយបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស និងសេដ្ឋកិច្ចជាតិ ដោយសារព្រះសង្ឃមានសិទ្ធិជាអាទិភាពក្នុងការផ្សព្វផ្សាយ ដូចច្នេះព្រះសង្ឃអាចចូលរួមក្នុងការបញ្ច្រាប ការយល់ដឹងពីជំងឺផ្តាសាយបក្សីដល់ព្រះសង្ឃ ពុទ្ធបរិស័ទជិតឆ្ងាយតាមរយៈនៃការសម្តែងធម្មទេសនា ឬការចូលរួមក្នុងពិធីផ្សេងៗជាដើមបានយ៉ាងមានប្រសិទ្ធិភាព។ ចំនុចកត់សំគាល់ជាងនេះទៀត មេរៀនស្តីអំពីជំងឺផ្តាសាយបក្សី ត្រូវបានរៀបចំឡើងរួចរាល់ហើយដែលនឹងដាក់បញ្ចូលក្នុងកម្មវិធីសិក្សានៅឆ្នាំ ២០០៦-២០០៧នេះនៅកម្រិតសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ។

ការពង្រឹងសេវាបសុពេទ្យជាពិសេសតាមរយៈការបង្កើនសមត្ថភាព ក៏ដូចជាកាតូកិច្ចរបស់ភ្នាក់ងារពេទ្យសត្វភូមិក្នុងការពិនិត្យតាមដាន ឃ្លាំមើលស្ថានភាពសត្វ ចលនាសត្វ និងការផ្សព្វផ្សាយដល់ស្រទាប់កសិករចិញ្ចឹមសត្វបក្សីជាលក្ខណៈគ្រួសារប្រកបដោយវិធានការអនាម័យ និងដាក់ក្នុងទ្រុង គឺជាការងារអាទិភាពដែលត្រូវយកចិត្តទុកដាក់បន្ថែមទៀត ដើម្បីធានាបាននូវការការពារមិនអោយផ្ទុះឡើងនូវជំងឺកាចសាហាវនេះ

**ដើម្បីសុខភាពខ្លួនអ្នក គ្រួសារអ្នក និងសហគមន៍របស់អ្នក សូមកុំប៉ះពាល់ជាមួយសត្វបក្សីដែលសង្ស័យថា មានកើតជំងឺផ្តាសាយបក្សីហើយដាច់ខាតមិនត្រូវយកសត្វដែលងាប់ដោយសង្ស័យថាបណ្តាលមកពីជំងឺនេះមកធ្វើជាម្ហូបឡើយ**

## ផលប៉ះពាល់នៃថ្នាំពុលកសិកម្មទៅលើសុខភាព

ជាទូទៅបច្ច័យអាក្រក់ទាំងឡាយតែងតែកើតមានជានិច្ចចំពោះកសិកម្មខ្មែរនៅពេលប្រើប្រាស់ថ្នាំពុលគីមីសំលាប់សត្វល្អិត បើទោះមានវិធានការការពារយ៉ាងណាក៏ដោយ ក៏តិច ឬច្រើនសារធាតុគីមីតែងយាយី បំផ្លាញដល់សុខភាពជានិច្ច ដោយហេតុផលនេះហើយទើប ពត៌មានសំខាន់សំរាប់អ្នក លេខនេះសូមដកស្រង់ទាំងស្រុង នូវអត្ថបទមួយដែលបានចុះផ្សាយនៅលើទំព័រទស្សនាវដ្តីកសិករលេខចេញផ្សាយឆ្នាំទី៧លេខ៨២ តុលា ២០០៥ដើម្បីលើកយកមកបង្ហាញជូនមិត្តអ្នកអាន នូវផលប៉ះពាល់ថ្នាំពុលដែលកសិករ**ឈឹន យឹម** នៅស្រុកកោះសូទិន ខេត្តកំពង់ចាម បានជួបប្រទះដូចតទៅ ៖

បងស្រី**ឈឹន យឹម** អាយុ ៣៨ឆ្នាំ ជាកសិកររស់នៅភូមិកំពង់ស្តីក្រោម ឃុំកំពង់រាបស្រុកកោះសូទិន ខេត្តកំពង់ចាម នៅក្នុងគ្រួសាររបស់គាត់ មានសមាជិក ៥នាក់ និងមានផ្ទៃដីធ្វើស្រែប្រាំង និងដាំដំណាំសរុប១ហិចតា។ នៅក្នុងភូមិរបស់គាត់មានការប្រើប្រាស់ថ្នាំពុលស្ទើរតែទូទៅ ដើម្បីការពារ និងកំចាត់កក្កាចង្រៃដែលបំផ្លាញដំណាំគាត់ គិតជាមធ្យមចំណាយក្នុងការទិញថ្នាំក្នុងមួយគ្រួសារប្រហែល៣០ម៉ឺនរៀល ការចំណាយលើជីគីមី ជាមធ្យម ១០០គីឡូ ក្រាមក្នុងមួយគ្រួសារ ស្មើនឹងទឹកប្រាក់ ចំនួន១២ ម៉ឺនរៀល។

**១. ប្រវត្តិនៃការប្រើប្រាស់ថ្នាំពុល:**

បងស្រី បានប្រើថ្នាំពុលតាំងពីឆ្នាំ ២០០០ តាមរយៈអ្នកជិតខាងរបស់គាត់។

# កសិកម្ម និងការអភិវឌ្ឍន៍

ចំពោះប្រភេទថ្នាំពុលដែលគាត់ប្រើមេថ្នាំ (១២ :០០ abamextin) ថ្នាំទង់ជ័យ (ABABEST) ថ្នាំ ៧០% (Mathamidophos) ទឹកស្អាត ឬក្លិនស្អុយ (DP-50 Dichlovose) និងថ្នាំសញ្ញាស្លឹកឈើបី (Viphensa) លាយបញ្ចូលគ្នា រួចយកទៅបាញ់លើដំណាំបន្លែ។ ចំពោះដំណាំស្រូវគាត់ប្រើថ្នាំក្បាលខ្មៅ(Folidol)ដើម្បីកំចាត់ស្រឹង។

នៅក្នុងគ្រួសារ ជាទូទៅប្តីបងស្រីមានតួនាទីជាអ្នកបាញ់ថ្នាំ តែដោយសារការខ្វះជីវភាព គាត់ត្រូវបង្ខំចិត្តទៅរកកំរៃបន្ថែមនៅក្រៅស្រុក ដូច្នេះការបាញ់ថ្នាំត្រូវធ្លាក់មកលើបងស្រីជាអ្នកទទួលខុសត្រូវពេលប្តីមិននៅ។

**២.ផលប៉ះពាល់នៃការប្រើប្រាស់ថ្នាំពុលកសិកម្ម**

ដោយសារតែពុំបានយល់ដឹងពីគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់ថ្នាំពុល ធ្វើអោយគាត់ប្រើដោយគ្មានការខ្លាចរអារ។ នៅក្នុងឆ្នាំ ២០០០ បងស្រីធ្លាប់បានពុលធ្ងន់ធ្ងរ ម្តងដោយសារការបាញ់ពុំបានមើលទិសខ្យល់ គាត់បាញ់បញ្ច្រាសខ្យល់ និងពុំបានពាក់ម៉ាស់ការពារកុំអោយថ្នាំសាចមកលើខ្លួនវិញធ្វើអោយប្រលាក់ជាតិថ្នាំមកលើជើងពេលគាត់ដើរកាត់ចំការបាញ់ថ្នាំចុះឡើង ។

នៅពេលបាញ់បានប្រហែលជាកន្លះម៉ោង គាត់ចាប់ផ្តើមឈឺក្បាល វិលមុខ ធឹងធោង ត្រជាក់ដៃជើង និងញ័រទ្រូង ថប់ៗដង្ហើម ឃើញសភាពមិនស្រួល គាត់ប្រញាប់រូតរះឡើងមកសំរាកដោយយកស្ករមកហូបដើម្បីបន្សាបថ្នាំរហូតដល់រយៈពេលមួយម៉ោងក្រោយមក ទើបអាចមកបន្តបាញ់ថ្នាំទៀតបាន។ ហើយអាការៈបែបនេះគាត់ឧស្សាហ៍ជួបញឹកញាប់ណាស់តែគាត់គិតថាវាមិនមានបញ្ហាអ្វីទេព្រោះមិនបានចាប់អារម្មណ៍ថាវាជាអាការៈនៃការពុលទេ។ ទើបមកដល់បច្ចុប្បន្ននេះ គាត់សង្កេតឃើញថាសុខភាពគាត់មានការចុះខ្សោយជាងមុន ដូចជាឧស្សាហ៍ខ្យល់ចាប់ មានជំងឺស្រឹតចុករោយកំភួនជើង ជួនកាលស្ពឹកចុងដៃ កាន់អ្វីមិនសូវជាប់ ស្រវាំងភ្នែកមើលអ្វីដូចជាបែកផ្សែង ហូបអ្វីឆាប់ណែនពោះ និងមានអារម្មណ៍ឆាប់ឆេវឆាវជាងមុន ។ បងស្រីបន្ថែមថា ក្នុងកំឡុងពេលគាត់មានផ្ទៃពោះ ដោយសារប្តីគាត់មិននៅ គាត់ទទួលការបាញ់ថ្នាំជំនួសកាលណោះដោយសត្វមានការបំផ្លាញច្រើនគាត់បានប្រើថ្នាំច្រើនមែនទែន។ គាត់សំគាល់ឃើញថា កូននេះកើតមកខុសពីកូនមុនៗ វាមានសុខភាពមិនល្អឡើយ ឧស្សាហ៍ឈឺ មិនសូវមានកំលាំងកំហែង មានសភាពមិនសូវរឹងមាំរហូតដល់អាយុ៣ឆ្នាំ ទើបអាចដើរបាន។ បច្ចុប្បន្នកូនគាត់អាយុ៥ឆ្នាំហើយ តែនៅមិនទាន់រឹងប៉ឹង និងមិនសូវមានសាច់ឈាមនឹងគេទេ ម្យ៉ាងវិញទៀតវាហាក់ដូចជាល្ងង់ មិនសូវឆ្លាត និងមានស្មារតីតិច ឆាប់ភ័យ។

ទើបតែនៅឆ្នាំ២០០៥នេះ ក្រោយពេលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរបស់អង្គការសហគមន៍ខ្មែរ ដើម្បីអភិវឌ្ឍន៍ (DKC) សហការជាមួយអង្គការសេដាក ស្តីពីការអនុវត្តការងារកសិកម្មតាមគោលការណ៍ធម្មជាតិ និងបានបង្ហាញពីផលប៉ះពាល់ដែលបណ្តាលមកពីការប្រើប្រាស់ថ្នាំពុលកសិកម្មរួចមកនោះ ទើបធ្វើអោយគាត់មានការព្រួយបារម្ភពីសុខភាពរបស់គាត់ និងក្រុមគ្រួសារគាត់យ៉ាងខ្លាំង។ បងស្រីមានប្រសាសន៍ថា ចាប់ពីពេលនេះតទៅគាត់នឹងខិតខំកែច្នៃថ្នាំពុលផ្សំពីរុក្ខជាតិសំរាប់ប្រើជំនួសវិញនិងផ្សព្វផ្សាយដល់កសិករក្នុងភូមិគាត់ដើម្បីអោយអ្នកភូមិគាត់បានយល់ និងឈានទៅកាត់បន្ថយការប្រើប្រាស់សារធាតុគីមី។ បងស្រីបានបន្ថែមថា គាត់ចង់អោយកសិករនៅភូមិគាត់ឈប់ប្រើសារធាតុគីមី ហើយងាកមកប្រើធនធានក្នុងស្រុកវិញ ដើម្បីកាត់បន្ថយថវិកា និងការប៉ះពាល់ដល់សុខភាព និងបរិស្ថាន។

**ពីបំណងល្អរបស់ ពត៌មានសំខាន់សំរាប់អ្នក សូមប្រជាកសិករទាំងអស់កាត់បន្ថយអោយបានជាអតិបរមានូវការប្រើប្រាស់ថ្នាំពុលកសិកម្មហើយងាកមកអនុវត្តតាមគោលការណ៍ធម្មជាតិវិញ ជាការល្អជាងព្រោះវាមិនបណ្តាលអោយប៉ះពាល់ដល់សុខភាព គុណភាពដី និងបរិស្ថាន ព្រមទាំងត្រូវបានចំណាយថវិកាតិចតួច តែទទួលបាននូវទិន្នផលច្រើនទៀតផង។**

**ប្រសិនបើត្រូវការប្រើប្រាស់ថ្នាំពុលកសិកម្មទាំងនោះជៀសមិនរួច សូមប្រុងប្រយ័ត្នប្រើប្រាស់វា អោយបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ជាពិសេសក្នុងការការពារ មិនអោយជាតិថ្នាំសាយភាយប្រលាក់ខ្លួន ដែលនឹងធ្វើអោយខូចសុខភាពបាន ទោះបីមិនមែននៅពេលបច្ចុប្បន្ននេះ តែនៅពេលអនាគតនឹងជួបប្រទះបញ្ហាធ្ងន់ធ្ងរ ជៀសមិនផុតឡើយ ទាំងខ្លួនអ្នក ទាំងកូនរបស់អ្នកជំនាន់ក្រោយទៀតផង។**



# ទំព័រធនធានធម្មជាតិ និងបរិស្ថាន

## ការស្វែងយល់ពីកិច្ចការពារបរិស្ថាន នៅប្រទេសជប៉ុន

បើនិយាយពីស្ថានភាពបរិស្ថាននៅប្រទេសកម្ពុជាវិញ យើងត្រូវបានទទួលស្គាល់ការពិតថា មានកំរិតទាប ទំលាប់របស់ប្រជាពលរដ្ឋនៅខ្សោយនៅឡើយ នៅក្នុងការចូលរួមធ្វើអោយបរិស្ថានស្អាត។ ដើម្បីបង្ហាញជាគំរូអំពីការការពារបរិស្ថាន ពត៌មានសំខាន់សំរាប់អ្នក លេខនេះសូមដកស្រង់ទាំងស្រុងនូវអត្ថបទមួយ ដែលចុះផ្សាយនៅលើទំព័រការសែតកោះសន្តិភាពលេខ៥៨៨៧ ថ្ងៃព្រហស្បត៍ ទី២៨ ខែកញ្ញា ឆ្នាំ២០០៦ ទាក់ទងនឹងការពារបរិស្ថាន នៅប្រទេសជប៉ុន មកជំរាបជូនដូចតទៅ ៖

ដោយជីវភាពកាន់តែទំនើប កាន់តែមានផាសុខភាព និងកាន់តែស្រួលនោះក៏កើតមាននិន្នាការរីកចំរើនដើម្បីធ្វើវាប្រើតែម្តងហើយគ្រវាត់ចោល។ ប្រការនេះបានបណ្តាលអោយមានបញ្ហាយ៉ាងច្រើនដល់បរិស្ថាន រួមមានការបំពុលខ្យល់អាកាស និងទឹកការខូចខាត អន្ត-រាយដល់បរិស្ថានធម្មជាតិ កំនើនកំដៅសកល និងបរិមាណដ៏ច្រើនសន្ធឹកសន្ធាប់នៃកាកសំណល់។ ការការពារបរិស្ថាន គឺជាភារកិច្ចមួយដ៏សំខាន់មិនត្រឹមតែចំពោះប្រទេសជប៉ុន ប៉ុណ្ណោះទេ ក៏ប៉ុន្តែចំពោះពិភពលោកទាំងមូលផងដែរ។ ដឹកនាំដោយរដ្ឋាភិបាលជប៉ុន ប្រជាជនជប៉ុននាពេលនេះបានចូលរួមយ៉ាងសកម្មក្នុងការខិតខំការពារបរិស្ថានក្នុងទ្រង់ទ្រាយដ៏ធំដែលបានចូលរួមមិនត្រឹមតែចំពោះប្រទេសជប៉ុនប៉ុណ្ណោះទេ ក៏ប៉ុន្តែចំពោះពិភពលោកទាំងមូលផងដែរ។ តំលៃនៃភាពងាយស្រួលរបស់ជីវភាពទំនើបគឺជាការបង្កើតឡើងនូវកាកសំណល់ដ៏ច្រើន។ បើសិនជាគេយកកាកសំណល់ទាំងនោះ ទៅកប់ចោលនៅកន្លែងកប់កាកសំណល់លទ្ធផលគឺគេជួបនូវគំនរសំរាមច្រើនឡើងៗដូចភ្នំ។

ជប៉ុនសំរេចបានយ៉ាងច្រើន ក្នុងការកាត់បន្ថយបរិមាណនៃសំរាមនិងក្នុងការប្រើផលិតផលសារចុះសារឡើងអោយអស់លទ្ធភាពរបស់វា។ ការប្រើកំប៉ុងដបប្លាស្ទិចសារចុះសារឡើង គឺជាវិធីមួយដែលគេរៀបចំបានយ៉ាងល្អ ជាពិសេសក្នុងប្រទេសជប៉ុន។

**ជីវភាពប្រកបដោយផាសុខភាព តំរូវអោយមានថាមពលច្រើន រួមមានអគ្គិសនី ឧស្ម័ន និងប្រេងឥន្ទនៈ។ ការផលិតអគ្គិសនី និងការប្រើម៉ាស៊ីនអោយដើរដោយដុតប្រេងឥន្ទនៈ ដូចជាប្រេង និងធ្យូងថ្ម បានភាយចេញនូវជាតិកាបូនឌីអុកស៊ីត និងឥស្ម័នដទៃទៀតនៅក្នុងខ្យល់អាកាស ហើយឧស្ម័នទាំងនេះបង្កអោយមានបញ្ហា ដូចជាកំនើនកំដៅសាកល និងការបំពុលខ្យល់។ កំនើនកំដៅសាកល គឺជាបញ្ហាមួយដែលក្នុងនោះ សីតុណ្ហភាពជុំវិញពិភពលោកបានកើនឡើង។ ដើម្បីបង្ការកុំអោយមានបញ្ហាទាំងនេះ គេត្រូវ កាត់បន្ថយបរិមាណនៃកាបូនឌីអុកស៊ីត និងឧស្ម័នផ្ទះកញ្ចក់។**

នៅឯ COP3 សន្និសិទ្ធមួយស្តីពីការទប់ស្កាត់កំនើនសាកល ត្រូវប្រារព្ធធ្វើឡើងនៅទីក្រុងជប៉ុន(ក្យូតូ) ក្នុងឆ្នាំ ១៩៩៧ ដែលប្រទេសជាច្រើន បានសន្យាថានឹងកាត់បន្ថយបរិមាណនៃឧស្ម័ន ដែលកើតចេញពីផ្ទះកញ្ចក់។

វិធីសាស្ត្រក្យូតូព្រមព្រៀងគ្នានៅក្នុងកិច្ច-ប្រជុំបានចូលជាធរមាន ក្នុងខែកុម្ភៈ

មធ្យោបាយមួយ នៃការកំចាត់កំដៅកំនើនកំដៅសាកល គឺត្រូវប្រើថាមពលដែលបរិសុទ្ធ មិនបង្កអោយមានការបញ្ចេញឧស្ម័នថាមពលព្រះអាទិត្យ ថាមពលខ្យល់ និងថាមពលកំដៅក្នុងផែនដីគឺសុទ្ធតែជាប្រភេទខ្លះនៃថាមពលបរិសុទ្ធស្អាតដែលអាចមាន។ជប៉ុនកំពុងតែពង្រីក និងផ្តើមយ៉ាងសកម្មនូវថាមពលបរិសុទ្ធជាផ្នែកមួយនៃការខិតខំដើម្បីដោះស្រាយបញ្ហាកំណើនកំដៅសាកល និងកាត់បន្ថយភាពកខ្វក់។

ជប៉ុន កំពុងខិតខំជួយបណ្តាប្រទេសជុំវិញ ដោះស្រាយបញ្ហាបរិស្ថានដោយផ្តល់អោយប្រទេសទាំងនោះ នូវបច្ចេកវិទ្យាបរិស្ថានសំរាប់តំរូវអោយគេអាចប្រើប្រាស់របស់សារចុះសារឡើងបាន និងកាត់បន្ថយឧស្ម័នដែលភាយចេញពីផ្ទះកញ្ចក់ ។

**ពីបំណងល្អរបស់ពត៌មានសំខាន់សំរាប់អ្នក សូមប្រជាពលរដ្ឋទាំងអស់រួមគ្នាការពារបរិស្ថាននៅតាមគេហដ្ឋាន ទីសាធារណៈអោយបានស្អាត ដើម្បីជាបឋមសំរាប់សុខភាពរបស់ខ្លួនយើង គ្រួសារយើង សហគមន៍យើង និងជាមុខមាត់ កិត្តិយសរបស់ប្រទេសជាតិយើង ។**



A balanced ecosystem existing within larger ecosystems

# ជីវិត និងសង្គម

## និមិត្តរូបបាតដៃស្អាតស្អំ និងអំពើពុករលួយនៅក្នុងសង្គមកម្ពុជា

ដោយមិនចាំបាច់រ៉ាយរ៉ាប់ច្រើនអំពីប្រភេទនៃអំពើពុករលួយនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន គ្រប់គ្នាទាំងអស់សុទ្ធតែដឹងថាអំពើពុករលួយ ជាចំណងមួយដែលបានចាក់ស្រេះយ៉ាងស្មុគស្មាញ ពិបាកនឹងធ្វើការស្រាយរំលារ ធ្ងន់ធ្ងរជាងនេះទៀតនោះច្បាប់ប្រឆាំងអំពើពុករលួយដែលរដ្ឋាភិបាលកម្ពុជា បានសន្យាថានឹងត្រូវធ្វើអោយរួចនៅត្រឹមដំណាច់ខែមិថុនាឆ្នាំនេះ នោះនៅមិនទាន់លេចចេញជារូបរាងនៅឡើយ។ ផលវិបាកនៃអំពើពុករលួយ គឺនាំល្បឿននៃការអភិវឌ្ឍន៍មានដំណើរការទៅយ៉ាងយឺតៗ ដែលជាហេតុនាំអោយការរស់នៅរបស់ប្រជាពលរដ្ឋភាគច្រើន នៅតែស្ថិតក្រោមបន្ទាត់ភាពក្រីក្រ កាលណាជីវភាពរបស់ប្រជាពលរដ្ឋមានភាពអន់ថយ ធ្វើអោយសេដ្ឋកិច្ចជាតិ ក៏មានភាពអន់ថយតាមនោះដែរ ។

ជាការងាយស្រួលទេ ដើម្បីបញ្ជាក់ថាតើពិតជាមានអំពើពុករលួយមែនដែររឺទេនៅក្នុងសង្គមកម្ពុជា ជាពិសេសនៅក្នុងជួររដ្ឋាភិបាល?យើងគ្រាន់តែសំលឹងមើលអំពីជីវភាពរស់នៅរបស់បណ្តាមន្ត្រីភាគច្រើនបំផុតនៅក្នុងប្រទេសកម្ពុជា មានជីវភាពរស់នៅយ៉ាងសប្បាយហ៊ឹហា ឡាន វីឡា ដុល្លា មានសព្វសារពើ ប៉ុន្តែសួរថាតើមន្ត្រីទាំងនោះ ទទួលបានប្រាក់បៀវត្សប៉ុន្មានក្នុងមួយខែ? វាសក្តិសមគ្នាដែររឺទេរវាងប្រាក់ឧបត្ថម្ភ និងទ្រព្យសម្បត្តិដែលពួកគេមាន? រាជរដ្ឋាភិបាលកម្ពុជាបានទទួលប្រាក់កម្ចីរាប់រយលានដុល្លាក្នុងមួយឆ្នាំៗពីបណ្តាប្រទេសផ្តល់ជំនួយនានាលើពិភពលោកអស់រយៈពេលជាងដប់ឆ្នាំកន្លងមក ហើយប៉ុន្តែយើងសង្កេតឃើញថាមានការរីកចំរើន ដល់កំរិត ណាហើយ? នេះមិនទាន់រាប់បញ្ចូល អំពីជំនួយឥតសំណងផ្សេងៗទៀតដែលផ្តល់អោយតាមរយៈអង្គការជាតិ និងអន្តរជាតិនៅឡើយផងទេ។ សូមចងចាំផងដែរណា ប្រាក់កម្ចីដែលរដ្ឋាភិបាលបាននិងកំពុងខ្ចីពីបរទេសនោះប្រជាពលរដ្ឋខ្មែរគ្រប់រូបគ្រប់ជំនាន់ ជាអ្នកត្រូវសងបំណុលទាំងនោះ ដែលមានរហូតមកដល់ពេលនេះមានរាប់ពាន់លានដុល្លាទៅហើយ ។ នាពេលថ្មីៗនេះចាត់ទុកជាសកម្មភាពនិងភាសាដ៏ចំលែកមិនធម្មតាមួយរបស់ឯកអគ្គរាជទូតប្រទេសជប៉ុនប្រចាំនៅកម្ពុជា ដែលជានិច្ចកាលមិនសូវសំដែងចេញនូវកង្វល់ជំទាស់នឹងវិធានការរបស់រាជរដ្ឋាភិបាលខ្មែរនោះ លោកហាសី ហ្វូមីអាគី បានបន្ទោសរដ្ឋាភិបាលដោយចំៗចំពោះការខកខានរបស់ខ្លួននៅក្នុងការឆ្លងច្បាប់ប្រឆាំងអំពើពុករលួយ ដែលបង្ហាញថារដ្ឋាភិបាលខ្វះអារម្មណ៍នៃភាពបន្ទាន់អំពីពុករលួយដែលក្រុមអ្នកផ្តល់ជំនួយត្រូវការដឹងអំពីគំរោងពេលច្បាស់លាស់សំរាប់ការអនុម័តច្បាប់នោះដែលត្រូវបានជជែកពិភាក្សាអស់រយៈពេល ១២ឆ្នាំកន្លងមកហើយ។ ការលើកឡើងបែបនេះរបស់ឯកអគ្គរាជទូតជប៉ុនគឺនៅក្នុងកំឡុងពេលប្រជុំរវាងរដ្ឋាភិបាល និងក្រុមអ្នកផ្តល់ជំនួយធំៗ កាលពីថ្ងៃទី០៥ ខែតុលាដោយលោកបាននិយាយទៀតថាថ្ងៃនេះយើងបង្ហាញការសោកស្តាយរបស់យើងដែលរាជរដ្ឋាភិបាលមិនទាន់បានដាក់សេចក្តីព្រាងច្បាប់របស់ពួកគេស្តីពីការប្រឆាំងអំពើពុករលួយទៅរដ្ឋសភាដែលសន្មតត្រូវធ្វើរួចនៅដំណាច់ខែមិថុនាឆ្នាំនេះ យើងមានការខកចិត្តទៅលើកិច្ចប្រឹងប្រែងធ្វើដោយរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងបញ្ហាប្រឆាំងអំពើពុករលួយ។ អំពើពុករលួយនៅក្នុងប្រទេសកម្ពុជាមានវិសាលភាពធំធេង ដែលផ្តល់ជាកង្វល់យ៉ាងខ្លាំងក្លា ដល់ប្រជាពលរដ្ឋទូទៅរបស់ប្រទេសនេះរួមទាំងអង្គការសង្គមស៊ីវិល ក៏ដូចជាក្រុមអ្នកផ្តល់ជំនួយ។ ដើម្បីបង្ហាញនូវការចាប់អារម្មណ៍ការបារម្ភរបស់ខ្លួន និងជាយុទ្ធនាការជំរុញអោយស្ថាប័នដឹកនាំជាតិយកចិត្តទុកដាក់ប្រឆាំងនឹងអំពើពុករលួយកាលពីថ្ងៃទី០៩ខែតុលាឆ្នាំ២០០៦ តំណាងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២០ បានដង្ហែសន្លឹសញ្ញានិមិត្តរូបបាតដៃស្អាតស្អំ សរុបចំនួន ១១៣ ១១២ ច្បាប់ដែលចុះហត្ថលេខាដោយប្រជាពលរដ្ឋមកពីគ្រប់ផ្នែកនៃសង្គម ទៅកាន់រដ្ឋសភាដើម្បីយកប្រគល់ជូនអ្នកតំណាងរាស្ត្រទាំងបីគណបក្សដែលមានអសនៈនៅរដ្ឋសភាដើម្បីពិនិត្យនិងអនុម័តច្បាប់នេះអោយបានលឿនក្នុងការទប់ស្កាត់អំពើពុករលួយ។ អង្គការលីកាដូ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា អង្គការខុមប្រែល អង្គការផេកកម្ពុជា និងអង្គការសង្គមស៊ីវិលជាច្រើនទៀតដែលស្ថិតនៅក្នុងក្បួនដង្ហែនោះ បានបញ្ជាក់យ៉ាងច្បាស់លាស់ថាយើងទាំងអស់គ្នាជាសង្គមស៊ីវិល និងប្រជាពលរដ្ឋខ្មែរសូមអោយច្បាប់ប្រឆាំងអំពើពុករលួយនេះអនុម័តអោយបានឆាប់ ហើយមានលក្ខណៈជាអន្តរជាតិ ព្រមទាំងអោយមានការថែងអំពីការប្រកាសទ្រព្យសម្បត្តិរបស់មន្ត្រីរាជរដ្ឋាភិបាលមុនពេលចូលកាន់តំណែង។ គួរបញ្ជាក់ផងដែរថាសន្លឹសញ្ញានិមិត្តរូបបាតដៃស្អាតស្អំបាននិយាយអំពីបញ្ឈប់អំពើពុករលួយចាប់ពីខ្លួនយើងទៅ រួមគ្នាប្រឆាំងអំពើពុករលួយ ហើយវាគឺជាសេចក្តីថ្លែងអំពីការព្រួយបារម្ភរបស់ប្រជាពលរដ្ឋខ្មែរចំពោះការគំរាមកំហែង នៃអំពើពុករលួយដល់ស្ថេរភាព ការអភិវឌ្ឍន៍សង្គម និងអនាគតរបស់ប្រទេសកម្ពុជា ។

**ជាគំនិតដ៏ស្មោះស និងបំណងដ៏ល្អពីពត៌មានសំខាន់សំរាប់អ្នក សូមយុវវ័យសិស្ស និស្សិត ដែលជាអ្នកចេះដឹង ជាអនាគតអ្នកបន្តវេនក្នុងការដឹកនាំប្រទេស**

# ជីវិត និងសង្គម

ជាតិ សូមលះបង់អោយអស់នូវគំនិតមហិច្ឆតាលោភលន់ចង់បានទ្រព្យសម្បត្តិដែលបានមកដោយសារអំពើពុករលួយ ស៊ីសំណូកសូកប៉ាន់ បក្សពួកនិយម និងសូមយុវវ័យ សិស្ស និស្សិតទាំងអស់ជួយផ្សព្វផ្សាយ អប់រំណែនាំបន្តដល់អ្នកនៅជុំវិញខ្លួនទាំងអស់អោយបញ្ឈប់ និងកុំប្រព្រឹត្តិអំពើ ពុករលួយតទៅទៀត ។ ស្អាតស្អំទាំងអស់គ្នា ដើម្បីអនាគតខ្លួនយើង គ្រួសារយើង ប្រទេសជាតិយើងរុងរឿងថ្កើងថ្កាន និងថ្លៃថ្នូរ។

---

## ភាពពិត នៃកីឡាកម្ពុជា

ជាការគួរអោយកោតសរសើរមួយដល់ស្ថាប័នកីឡារបស់ព្រះរាជាណាចក្រកម្ពុជា ដែលនាពេលថ្មីៗនេះ បានរៀបចំការប្រកួត ជ្រើសរើសជើងឯកទូទាំងប្រទេសជាលើកទី១ នូវក្បាច់គុណខ្មែរល្បុក្កតោ ដែលស្ទើរតែបាត់ទៅហើយនៅក្នុងអាណាចក្រនេះ។ជាការគួរអោយមោទនភាពដ៏ធំសម្បើមជាងនេះទៀតនោះ នៅក្នុងការប្រកួតប្រជែងកីឡាក្បាច់គុណល្បុក្កតោនេះ មានកីឡាករកីឡាការនីសរុបចំនួន ៣០៧ នាក់មកពីបណ្តាខេត្តនានាបានដោយរាប់ទាំងលោកយាយម្នាក់ឈ្មោះ**ម៉ៅ ខាន់** ដែលមានអាយុ៨០ឆ្នាំទៅហើយនោះបានចូលរួមផងដែរ។ គ្រាន់តែចំនុចនេះអាចបង្ហាញយ៉ាងច្បាស់ថាវាមិនមានបញ្ហាទេចំពោះធនធានកីឡាករ កីឡាការនីទាំងក្មេង ទាំងចាស់ ដែលមាននិស្ស័យនិងសមត្ថភាពពិតប្រាកដ នៅក្នុងវិស័យកីឡា មិនមែនសំរាប់តែកីឡាល្បុក្កតោដែលលើកមកបង្ហាញនាពេលនេះទេ តែក៏រាប់ផងដែរនូវកីឡាពេញនិយមដទៃទៀតដូចជាកីឡាបាល់ទាត់ បាល់ទះ កីឡាប្រដាល់ ហែលទឹក អត្តពលកម្ម... ប៉ុន្តែអ្វីដែលជាបញ្ហានោះ គឺការដឹកនាំស្ថាប័នកីឡា របស់អ្នកអន្ទ្រើសៗខាងកីឡាឯណោះវិញទេ ។

ជាក់ស្តែង ការប្រកួតប្រជែងលើកទីមួយនូវកីឡាល្បុក្កតោនេះ បានធ្វើអោយកីឡាករ កីឡាការនី គ្រូល្បុក្កតោជា ច្រើននាក់នៅតាមខេត្តមានការខឹងសម្បា ខកចិត្តយ៉ាងខ្លាំង ហើយធ្ងន់ធ្ងរជាងនេះទៀតនោះពួកគេបាននិយាយច្បាស់ៗថា នឹងមិនមកទៀតទេនៅលើកក្រោយ។ មានម្នាក់ក្នុងចំណោមនោះបាននិយាយយ៉ាងអស់សង្ឃឹមទៅនឹងការចាត់ចែងអោយពិន្ទុដ៏អយុត្តិធម៌របស់គណ:កម្មការប្រកួតថាខ្ញុំចង់អោយចំណេះល្បុក្កតោស្លាប់ជាមួយខ្ញុំ ប្រសើរជាងការបង្ហាញល្បុក្កតោដូច្នេះ អ្នកផ្សេងទៀតមិនអាចកេងចំណេញអ្វីបានទាំងអស់។ តើអស់លោកគិតមើល មានការឈឺចាប់កំរិតណាអយុត្តិធម៌យ៉ាងណាទើបពាក្យសំដីដ៏មោះមុតទាំងនេះបានបន្លឺចេញមក? ហើយពត៌មានសំខាន់សំរាប់អ្នក គិតថាកាលបើបានលឺសំដីនេះហើយ គណ:កម្មការ រឺអ្នករៀបចំប្រកួតកីឡាប្រភេទនេះ គួរតែចាប់អារម្មណ៍ និងយកមកឆ្លុះបញ្ចាំងឡើងវិញអំពីដំណើរការ និងការចាត់ចែងរបស់ខ្លួន ប៉ុន្តែផ្ទុយទៅវិញអ្នករៀបចំការប្រកួត បាននិយាយយ៉ាងសើងម៉ើងថា ការមានភាពចម្រូងចម្រាស រឺការធ្វើពហិការមិនបានធ្វើអោយគាត់បារម្ភទេ យើងមិនបារម្ភអំពីក្បាច់គុនល្បុក្កតោចុះខ្សោយដោយសារមនុស្សចាស់២០នាក់ដែលមិនសប្បាយចិត្តនោះទេ។ ប្រសិនបើអ្នករៀបចំ រឺអ្នកដឹកនាំកីឡានិយាយតែបែបនេះ តើយើងមានសង្ឃឹមថាវិស័យកីឡារបស់ខ្មែរយើងនឹងនៅតែមិនអាចប្រៀបធៀបជាមួយប្រទេសជិតខាងរឺតំបន់រហូតដល់ពេលណា? នេះមិនខុសអ្វីពីពេលកន្លងមក ដែលយើងធ្លាប់តែឮយ៉ាងស៊ាំត្រចៀកពីអ្នកដឹកនាំកីឡា ពេលត្រលប់មកពីប្រកួតនៅប្រទេសក្រៅវិញថាពិតមែនតែយើងមិនបានទទួលមេដាយក៏ដោយ តែវាជាមោទនភាព និងបទពិសោធន៍សំរាប់ការពង្រឹងវិស័យកីឡារបស់យើង។ យើងឆ្ងល់ថាតើវាជាមោទនភាព និងបទពិសោធន៍ល្អពិតមែនរឺនៅពេលដែលយើងប្រកួតចាញ់គេនោះ? តើយើងនៅចង់បានមោទនភាព និងបទពិសោធន៍បែបនេះរយ:ពេលប៉ុន្មានឆ្នាំតទៅមុខទៀត? បើយើងរាប់ពីឆ្នាំ១៩៩៣នៅពេលដែលមានការបោះឆ្នោតរៀបចំឡើងដោយអ៊ុនតាក់រហូតដល់ពេលនេះមានរយ:ពេលជាងដប់ឆ្នាំហើយនោះ ។

នាពេលថ្មីៗនេះ សម្តេចនាយករដ្ឋ-មន្ត្រីបានរិះគន់ចំៗចំពោះស្ថាប័នដឹកនាំកីឡាអូឡាំពិកកម្ពុជាដែលធ្វើការចំណាយច្រើនហួសហេតុ និងមិនប្រក្រតីនៅក្នុងការវិស័យកីឡា។ការមិនយកចិត្តទុកដាក់ចំពោះជីវភាព សុខភាពកីឡាករ ការមិនលើកទឹកចិត្តដល់កីឡាករ និងការកេងប្រវ័ញ្ច យកប្រៀបពីលើកីឡាករនៅក្នុងការបញ្ជូនប្រតិភូហែហម ច្រើនជាងកីឡាករសំរាប់ការប្រកួតនៅបរទេសម្តងៗ ការជ្រើសរើស និងសំរេចសេចក្តីក្នុងការប្រកួតមិនយុត្តិធម៌ គឺជាកត្តាចំបងក្នុងការធ្វើអោយកីឡាខ្មែរមិនអាចមានឈ្មោះល្បី យកមេដាយជូនជាតិមាតុ-ភូមិបានដូចប្រទេសនានា។

ដោយបំណងល្អពីពត៌មានសំខាន់សំរាប់អ្នកក្នុងការលើកស្ទួយកេរ្តិ៍ឈ្មោះខាងកីឡានៅលើឆាកអន្តរជាតិ សូមស្ថាប័នកីឡាអ្នកដឹកនាំស្ថាប័នកីឡា យកចិត្តទុកដាក់លើកស្ទួយចំពោះជីវភាព សុខភាព និងទឹកចិត្តដល់កីឡាករ កីឡាការនី ជាងនរណាៗទាំងអស់ និងត្រូវប៊ានទទួលស្គាល់ការពិតនូវកំហុសឆ្គង និងកំសោយរបស់ខ្លួនដើម្បីពង្រឹងនិងកែលំអនូវចំនុចអវិជ្ជមានរបស់វិស័យកីឡា អោយរីកចំរើនពិតប្រាកដ។

# ទំព័រចុងក្រោយសំរាប់អ្នក

## ជំរើសល្អសំរាប់យុវវ័យ

តើលោក-អ្នកអាចឆ្លើយបានទេថា តើនៅក្នុងដំណាក់កាលយុវវ័យ តំរូវការអ្វីដែលសំខាន់ជាងគេនោះ ?

ពិតជាមិនពិបាកក្នុងការឆ្លើយនូវសំណួរនេះឡើយដោយហេតុថាបើលឺពីពាក្យថា យុវវ័យ អ្វីដែលជីវិតក្នុងដំណាក់កាលនេះត្រូវការសំខាន់បំផុតនោះគឺការសិក្សា និងស្នេហា។ ដំណាក់កាលយុវវ័យ គឺមានលក្ខណ:ពិសេសនៅក្នុងការងាយទទួលយកការចងចាំនិងចំណេះដឹងផ្សេងៗ ហេតុនេះការសិក្សាគឺមានលក្ខណ:អំណោយផលជាងពេលណាៗទាំងអស់របស់ជីវិតមនុស្ស។ តំរូវការមួយទៀតយុវវ័យគឺជាដំណាក់កាលដែលមានសមត្ថភាពពេញលេញនៅក្នុងការបន្តពូជ ដែលកត្តានេះជាគោលការណ៍ធម្មជាតិបានជំរុញអោយយុវវ័យបង្កើតនូវចំណងស្នេហាយ៉ាងក្តៅគគុក។ ប៉ុន្តែប្រសិនបើមានសំណួរដែលតំរូវអោយយុវវ័យជ្រើសរើសយកតែមួយ តើការសិក្សា រឺស្នេហា តើអ្នក សំរេចចិត្តយ៉ាងណា? ជំរើសនេះនឹងអាចមានផ្សេងៗគ្នា ដោយអាស្រ័យទៅតាមចំណង់ចំណូលចិត្តរៀងៗខ្លួន របស់យុវវ័យ ក្នុងនោះមានយុវវ័យមួយចំនួនជ្រើសរើសយកការសិក្សាហើយយុវវ័យមួយចំនួនទៀតជ្រើសរើសយកស្នេហា។ ប៉ុន្តែពីបំណងដ៏ល្អរបស់ ពត៌មានសំខាន់សំរាប់អ្នក សូមយុវវ័យទាំងអស់ ជ្រើសរើស និងផ្តល់អាទិភាពចំពោះការសិក្សាជាការល្អប្រសើរជាងដោយហេតុថាការសិក្សាអាចអោយអនាគតរបស់យុវវ័យមានភាពភ្លឺស្វាង និងរុងរឿង ការសិក្សានាំអោយអ្នកមានចំណេះដឹងមានចំណេះដឹងនាំអោយអ្នកទទួលបានជោគជ័យនៅក្នុងការងារ និងសំរេចបាននូវគោលបំណងដ៏ពិសិដ្ឋរបស់អ្នក ដោយរាប់ទាំងការនាំអ្នកអោយក្លាយទៅជាអ្នកដឹកនាំបានយ៉ាងមានប្រសិទ្ធិភាព ប៉ុន្តែផ្ទុយទៅវិញស្នេហា នឹងមិនអាចនាំអោយអ្នកក្លាយជាអ្នកចេះដឹងឡើយ គ្មានចំណេះដឹងអ្នកនឹងងាយធ្លាយចូលទៅក្នុងអំពើអបាយមុខនានាដូចជា ការសេពគ្រឿងញៀន ការប្រព្រឹត្តិតអំពើហឹង្សា និងអំពើអសីលធម៌នានា គ្មានចំណេះដឹងអ្នកមិនអាចប្រលងប្រជែងសំរាប់ទីផ្សារការងារបានជោគជ័យឡើយជាពិសេសជាងនេះទៀតនោះស្នេហានឹងបំផ្លាញការសិក្សារបស់អ្នកយ៉ាងមានប្រសិទ្ធិភាពដែលវាមានន័យស្មើនឹងការបំផ្លាញអនាគតរបស់អ្នកយ៉ាងដូច្នោះដែរ។

**ជឿចុះណាយុវវ័យទាំងឡាយ សូមផ្តល់អាទិភាព និងជ្រើសរើសយកការសិក្សាដើម្បីជីវិត និងអនាគតរុងរឿងរបស់អ្នក គ្រួសាររបស់អ្នក និងប្រទេសជាតិរបស់អ្នក ។**

សូមយុវវ័យទាំងអស់ចងចាំណា អ្នកនិងគ្រួសាររបស់អ្នក នឹងទទួលបាននូវការកោតសរសើរ និងផ្តល់កិត្តិយសយ៉ាងពេញចិត្តពីមជ្ឈដ្ឋាននៅជុំវិញរបស់អ្នក នៅពេលដែលអ្នកមានចំណាត់ថ្នាក់ល្អប្រសើរនៅក្នុងការសិក្សា ខ្លួនអ្នក និងគ្រួសារអ្នកនឹងសប្បាយរីករាយបំផុតនៅពេលដែលអ្នកទទួលបានរង្វាន់ពីការសិក្សា។ លទ្ធផលល្អពីការសិក្សារបស់យុវវ័យ គឺជាក្តីសង្ឃឹមយ៉ាងប្រពៃសំរាប់គ្រួសារអ្នក និងប្រទេសជាតិរបស់អ្នក។ ប្រទេសអាចមានការរីកចំរើនជឿនលឿនទៅបាន គឺពឹងអាស្រ័យជាចាំបាច់ទៅលើយុវវ័យ ដែលជាសសរទ្រូងរបស់ប្រទេសជាតិមានការសិក្សាជ្រៅជ្រះ មានចំណេះដឹងខ្ពង់ខ្ពស់។

ដូច្នេះសូមយុវវ័យទាំងអស់ខិតខំសិក្សា ដើម្បីអនាគតរុងរឿងសំរាប់ខ្លួនអ្នក គ្រួសារអ្នក និងប្រទេសជាតិរបស់អ្នក !!!

ទន្ទឹមនឹងនេះដែរ ពត៌មានសំខាន់សំរាប់អ្នក មិនបដិសេធនូវការមានស្នេហានៅក្នុងដំណាក់កាលយុវវ័យឡើយដោយសារវាជាគោលការណ៍ធម្មជាតិ ប៉ុន្តែសូមយុវវ័យទាំងអស់កំណត់ព្រំដែនអោយបានច្បាស់លាស់ សំរាប់ស្នេហារបស់ខ្លួន មានន័យថា កុំអោយស្នេហារបស់អ្នកបំផ្លាញការសិក្សា បំផ្លាញកត្តិយស បំផ្លាញសុខភាព និងបំផ្លាញអនាគតរបស់អ្នក។

ដើម្បីជាការចូលរួមចំណែកអោយស្នេហារបស់យុវវ័យមិនបំផ្លាញសុខភាព មិនបំផ្លាញអនាគតរបស់យុវវ័យ ពត៌មានសំខាន់សំរាប់អ្នក នៅក្នុងលេខនេះសូមណែនាំយុវវ័យទាំងអស់អោយស្គាល់នូវអស័យដ្ឋានគេហទំព័រដ៏សំខាន់មួយដែលអប់រំពីសុខភាពផ្លូវភេទទីមួយនៅក្នុងប្រទេសកម្ពុជាដែលត្រូវ បានគេរចនាឡើងជាភាសាខ្មែរដោយយុវវ័យខ្មែរ និងសំរាប់យុវវ័យខ្មែរទាំងអស់គ្នានោះ គឺ www.healthandlove.org ។

www.healthandlove.org ផ្តល់ព័ត៌មានអប់រំយ៉ាងត្រឹមត្រូវ និងមានសុវត្ថិភាពជាច្រើនទាក់ទងទៅនឹងសុខភាពបន្តពូជ មិត្តភាព និងស្នេហា គ្រឿងញៀន សុខភាពផ្លូវភេទ ការពន្យារកំណើត ជំងឺអេដស៍ និងកាមរោគ ការរមួតកូនដោយសុវត្ថិភាពនិងព៌ត័មានជាច្រើនទៀតដែលទាក់ទងទៅនឹងនារី និងបុរស។ គេហទំព័រនេះបង្កើតឡើងដោយអង្គការ **Friend International** ក្រោមការឧបត្ថម្ភពីស្ថានទូតអង់គ្លេសប្រចាំកម្ពុជា និងសហការជាមួយអង្គការមួយចំនួនទៀត។

**សូមផ្ញើរមតិរបស់លោក-អ្នកមក**
**យើងខ្ញុំដើម្បីធ្វើការចុះផ្សាយ**

E-mail: ard.info@yahoo.com